ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខៈ ៣៣៣/២៥ អលា.

# គោរពជូន

**ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ ឈន សាណាត អគ្គនាយក**
**នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ៖** សំណើសុំសម្របសម្រួលផ្តល់រថយន្តនគរបាលដឹកក្រុមជនល្មើស ចំនួន ០១គ្រឿង (ដែលអាចផ្ទុកជនល្មើសបានចំនួន ១០នាក់) ដើម្បីរៀបចំផលិតជាវីដេអូបទយកការណ៍ សម្រាប់ផ្សព្វផ្សាយក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ។

**យោង៖** ចំណារដ៏ខ្ពង់ខ្ពស់បំផុត ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយក្រុមហ៊ុន សាស្ត្រាហ្វីម (Sastra Film Production) ដើម្បីផលិតជាវីដេអូបទយកការណ៍ សម្រាប់ផ្សព្វផ្សាយក្នុងកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមគោរពស្នើសុំ **ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ អគ្គនាយក** ដើម្បីសម្របសម្រួលផ្តល់រថយន្តនគរបាលដឹកក្រុមជនល្មើស ចំនួន ០១គ្រឿង (ដែលអាចផ្ទុកជនល្មើសបានចំនួន ១០នាក់) ។

**កម្មវិធីថតនឹងប្រព្រឹត្តទៅនៅ៖ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ០៧:០០ នាទីយប់ ។**

*(សូមគោរពជូនភ្ជាប់៖ កម្មវិធី ០១ច្បាប់)*

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ អគ្គនាយក** មេត្តា**សម្របសម្រួលផ្តល់រថយន្តនគរបាលដឹកក្រុមជនល្មើស** តាមការស្នើសុំ ដោយអនុគ្រោះ។

សូម **ឯកឧត្តម អគ្គនាយក** មេត្តាទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

*ថ្ងៃ ......................ខែ......................ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២៥*

**អគ្គលេខាធិការ**

**ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់**

សូមទំនាក់ទំនង៖
លោក វ.ទោ ធន ដារ៉ាវិទ្ធ
០១៦ ៩០ ៨៩ ៨៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ១៨៥/.....គ.ជ.ប.ម

| ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី (វិមានសន្តិភាព) | |
|---|---|
| ចូល | លេខ: 3515 <br> ថ្ងៃទី 21.ត.ល.2025 <br> ម៉ោង: 8h38 |

ថ្ងៃ...ខែ...ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២៥

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ÷** សំណើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីរៀបចំ **ទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥** និងគោរពអញ្ជើញ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត** ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីដ៏មានសារសំខាន់នេះ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជា បានកំណត់យកថ្ងៃទី១២ ខែធ្នូ ជាថ្ងៃ ប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស ដើម្បីជាយុទ្ធនាការរួមគ្នា បង្កើតនូវប្រព័ន្ធសុវត្ថិភាពសម្រាប់ការពារប្រជាពលរដ្ឋឱ្យរួចផុតពីភាពងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាទស្សនវិស័យ នៃកម្មវិធីនយោបាយជាតិ សម្រាប់ នីតិកាលទី៧ នៃរដ្ឋសភា ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨។

ដើម្បីឱ្យទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ នេះ ប្រព្រឹត្តទៅប្រកបដោយបរិយាកាសអធិកអធម និងរឹតតែមានអត្ថន័យជ្រាលជ្រៅ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ÷**

- រៀបចំ **ទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ** ដ៏មានសារសំខាន់នេះ ដែលនឹងប្រព្រឹត្តទៅនៅរសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ នៅមជ្ឈមណ្ឌល សន្និបាត និងពិព័រណ៍កោះពេជ្រ
- សូមគោរពអញ្ជើញ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត** មេត្តាផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីថ្លែងសារដ៏មានសារសំខាន់ និងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ ជូនថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាល សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា ស្ថានតំណាងបរទេសប្រចាំកម្ពុជា តំណាងសាសនា កងកម្លាំង សិស្សនិស្សិត ប្រជាពលរដ្ឋ និងភ្ញៀវជាតិ អន្តរជាតិសរុបប្រមាណ ៣០០០អង្គ/នាក់ និងតម្រង់ទិសឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក៏ដូចជាថ្នាក់ក្រោមជាតិ មានមូលដ្ឋានបន្តដឹកនាំការអនុវត្តសកម្មភាពឱ្យរឹតតែមានប្រសិទ្ធភាព។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចធិបតីនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អភិសន្តិបណ្ឌិត ស សុខា**

21.10.25